# អ្នកការពារសិទ្ធិមនុស្ស
# អ្នកស្រី យ៉ោម បុប្ផា

ដោះលែង ១៥ នាក់
បញ្ឈប់អំពើហិង្សា

## ម្តាយមួយរូបទៀតពីសហគមន៍បឹងកក់ ដែលត្រូវបានឃុំខ្លួន

### ពត៌មានសង្ខេប

អាយុ៖ ២៩ ឆ្នាំ
សហគមន៍៖ បឹងកក់
ថ្ងៃចាប់ខ្លួន៖ ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១២
ថ្ងៃជំនុំជម្រះ ៖ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២
ពន្ធនាគារ៖ មណ្ឌលអប់រំកែប្រែទី២ (ព្រៃស)
ផ្តល់នាមអ្នកទោស នៃមនសិការ ដោយអង្គការ លើកលែងទោសអន្តរជាតិ



អ្នកស្រី បុប្ផា កំពុងតវ៉ាអំឡុងពេលសវនការសាលាឧទ្ធរណ៍លើសំណុំរឿងស្ត្រីបឹងកក់ទាំង១៣ កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២

//////////////////////////////////

អ្នកស្រី យ៉ោម បុប្ផា ស្ទើរតែភ្លេចនូវចំនួនដង ដែលអ្នកស្រីត្រូវបានគម្រាមកំហែងដោយអាជ្ញាធរ ដោយសារអ្នកស្រីបានចូលរួមក្នុងយុទ្ធនាការរបស់សហគមន៍បឹងកក់ (BKL)។

ក្នុងនាមជាតំណាងសហគមន៍បឹងកក់ អ្នកស្រី យ៉ោម បុប្ផា ដែលមានអាយុ ២៩ឆ្នាំ ហើយជាម្តាយម្នាក់នោះ គឺជា សកម្មជនដីធ្លីម្នាក់ ដែលពូកែនិយាយ ហើយជាបុគ្គលសំខាន់នៅក្នុងយុទ្ធនាការដ៏យូរអង្វែងរបស់សហគមន៍អ្នកស្រី ដើម្បីប្រឆាំងនឹងការបណ្តេញចេញដោយបង្ខំ។ អ្នកស្រីមិនបានចាំនូវចំនួនដង ដែលអ្នកស្រីត្រូវបានគេវាយដំក្នុងអំឡុងពេលធ្វើ ការតវ៉ានោះទេ ប៉ុន្តែអ្នកស្រីចងចាំយ៉ាងច្បាស់ពីការ ដែលត្រូវបានគេឆក់ចំនួនពីរដង ដោយដំបងឆក់ នៅខណៈ ដែលកំពុងតវ៉ាដោយអហិង្សា។

បន្ទាប់ពីសមាជិកទាំង ១៣ នាក់ នៃសហគមន៍បឹងកក់ ត្រូវបានចាប់ខ្លួនដោយហិង្សា និងតាមអំពើចិត្តកាលពីខែឧសភា ឆ្នាំ២០១២ នោះ អ្នកស្រី យ៉ោម បុប្ផា បានស្ថិតនៅជួរមុខនៅក្នុង យុទ្ធនាការទាមទារឲ្យមានការដោះលែងអ្នកទាំងនោះ។ អ្នកស្រី បានរក្សានូវឋានៈជាមនុស្សសំខាន់នៅគ្រប់ការតវ៉ា នានាបានក្លាយជាអ្នកនាំពាក្យដល់សារព័ត៌មាន សម្រាប់យុទ្ធនាការ ហើយអ្នកស្រីថែមទាំងមិនមានការភ័យខ្លាច ក្នុងការរិះគន់មន្ត្រីរាជរដ្ឋាភិបាលជាសាធារណៈផងដែរ។ ថ្មីៗនេះ (ការលេចធ្លោនេះ បានធ្វើឲ្យមានការចាប់អារម្មណ៍ពីអាជ្ញាធរ) អ្នកស្រី ត្រូវបានគេគម្រាមកំហែង ដោយពាក្យសំដី រំខាន និងបំភិតបំភ័យ។

ស្ថិតនៅក្នុងយុទ្ធនាការ ដើម្បីឲ្យមានការដោះលែងអ្នកតំណាងសហគមន៍បឹងកក់ ដែលបានជាប់ឃុំ នគរបាលបានព្យាយាមដាក់គោលដៅតែមួយទៅអ្នកស្រី យ៉ោម បុប្ផា។ បន្ទាប់ពីការតវ៉ា ដោយអហិង្សាមួយបានបញ្ចប់អ្នកឃ្លាំមើលរបស់អង្គការមិនមែនរដ្ឋាភិបាលជាច្រើន បានផ្តល់នូវក្បួនសុវត្ថិភាពជូនអ្នកស្រីត្រឡប់មកផ្ទះវិញ បន្ទាប់ពីនគរបាល បានទទួលបញ្ជាឲ្យ "ចាប់ខ្លួនម្នាក់ដែលមានពាក់ក្រមាខៀវនៅលើក្បាល" [យ៉ោម បុប្ផា]។

អ្នកស្រី យ៉ោម បុប្ផា ជាមនុស្សដែលមានគ្រួសារ មានកូន ប្រុសអាយុ ៨ ឆ្នាំម្នាក់ ឈ្មោះ លួស លីហួរ។ ស្វាមីរបស់អ្នកស្រី ជាកម្មករសំណង់ រីឯម្តាយរបស់អ្នកស្រី ដែលបានលែងលះជាមួយស្វាមីរបស់គាត់នៅឆ្នាំ១៩៩៩ គឺជាកសិករនៅខេត្ត កំពង់ឆ្នាំង។ ដើម្បីជួយផ្គត់ផ្គង់ជីវភាពគ្រួសារ អ្នកស្រី យ៉ោម បុប្ផា បានធ្វើការងារសិប្បកម្ម នៅក្នុងសហគមន៍បឹងកក់។

បច្ចុប្បន្ន អ្នកស្រី យ៉ោម បុប្ផា ស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្ន នៅឯពន្ធនាគារព្រៃស (មណ្ឌលអប់រំកែប្រែទី២ ឬ ម២) នៅរាជធានី ភ្នំពេញ។

ខុសពីករណីអ្នកតំណាងសហគមន៍បឹងកក់ទាំង ១៣នាក់ បទចោទប្រកាន់ប្រឆាំងនឹងអ្នកស្រី គឺមិនជាប់ពាក់ព័ន្ធនឹងវត្តមានរបស់អ្នកស្រីនៅក្នុងការតវ៉ា និងបាតុកម្មនោះឡើយ។ អ្នកស្រី ត្រូវបានដាក់ឲ្យជាប់ពាក់ព័ន្ធនឹងបទល្មើសវាយបុគ្គល ដែលត្រូវបានសង្ស័យថា ជាចោរលួចជំនួសវិញ យោងតាម មាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ប៉ុន្តែវាមិនមានចម្ងល់នោះទេ ដែលករណីនេះ ជាករណីទាក់ទងនឹងនយោបាយ។

អ្នកឃ្លាំមើលសិទ្ធិមនុស្សជឿជាក់ថា អ្នកស្រី យ៉ោម បុប្ផា ត្រូវបានដាក់ក្នុងបញ្ជីខ្មៅទៅហើយ ដែលបច្ចុប្បន្ន អ្នកស្រី កំពុងប្រឈមនឹង "គ្រោះថ្នាក់" ដែលត្រូវបានគម្រាម ដោយនគរបាលតាំងពីយូរណាស់មកហើយ។ អ្នកស្រីនឹង ត្រូវចូលខ្លួនក្នុងសវនាការជនុំជម្រះនៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ នៅសាលាដំបូងរាជធានីភ្នំពេញនាវេលាម៉ោង ២ រសៀល។ ប្រសិនបើរកឃើញនូវពិរុទ្ធភាព អ្នកស្រីនឹងប្រឈមមុខនឹងការជាប់ពន្ធនាគាររយៈពេលរហូតដល់ទៅ ៥ ឆ្នាំ ហើយ ពិន័យជា ប្រាក់ចាប់ពី ៤ ទៅ ១០ លានរៀល (១.០០០ ដុល្លារ ទៅ ២.៥០០ ដុល្លារ)។

អ្នកស្រី យ៉ោម បុប្ផា ត្រូវបានកំណត់ជាគោលដៅ ក៏ព្រោះតែភាពសកម្ម

*"អ្នកនៅក្នុងបញ្ជីខ្មៅហើយឥឡូវនេះ.... អ្នកនឹងមានគ្រោះថ្នាក់នាពេលឆាប់ៗនេះ"*

\- ពាក្យសំដីរបស់មន្ត្រីនគរបាលទៅកាន់អ្នកស្រី យ៉ោម បុប្ផា

និយមរបស់អ្នកស្រី។ អ្នកស្រី មិនមែនជាបុគ្គល ទីមួយនោះទេ ហើយអ្នកស្រីក៏មិនមែនជាបុគ្គលចុងក្រោយនោះដែរ។

អាជ្ញាធរកម្ពុជា មានប្រវត្តិជាយូរណាស់មកហើយ ក្នុងការបំបិទមាត់អ្នកដែលរិះគន់ និងធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌលើអ្នកដែលបង្កបញ្ហា រួចធ្វើឲ្យបញ្ហារួមតូច ដោយប្រើប្រាស់ប្រព័ន្ធតុលាការដែលប្រកាន់បក្សពួក និងធ្វើការមិន បានល្អ។ មនុស្សដែលប្រឈមនឹងគ្រោះថ្នាក់ភាគច្រើន គឺជា សកម្មជនដីធ្លី (អ្នក ដែលការពារសហគមន៍រងគ្រោះប្រឆាំងនឹងផលប្រយោជន៍ឧកញ៉ា ដែលជាអ្នកជំនួញដ៏មានអំណាច និងមានខ្នងបង្អែក។

ដោយមានប្រវត្តិបែបនេះ វាមិនអាចទៅរួចទេ ក្នុងការបន្ទាបតម្លៃនៃការគម្រាមកំហែង ដោយឥតលាក់លៀម ដែល ត្រូវបានធ្វើឡើង ចំពោះអ្នកស្រី យ៉ោម បុប្ផា នៅមុនពេលមានការចាប់ខ្លួនអ្នកស្រី។ អ្នកតំណាងសហគមន៍បឹងកក់ដទៃទៀត ត្រូវបានគេធ្វើឲ្យជឿថា ការចាប់ខ្លួនអ្នកស្រី គឺជាការប៉ុនប៉ងមួយផ្សេងទៀតនៅក្នុងយុទ្ធនាការ ដែលកំពុងបន្តក្នុងការបំភិតបំភ័យសហគមន៍ទាំងមូល។ ការពិត ដែលសកម្មជនដីធ្លីដ៏លេចធ្លោទីពីរ អ្នកស្រី ទឹម សាក់មុន្នី ដែលមកពីសហគមន៍ បុរីកីឡា ត្រូវបានចាប់ខ្លួននៅថ្ងៃបន្ទាប់ភ្លាមៗនោះ មិនបានបន្ថយការសង្ស័យរបស់ពួកគេនោះទេ។ ការពិត ដែលស្ត្រីទាំងពីររូបត្រូវបានគេឃុំខ្លួនបណ្ដោះអាសន្ន ដោយមិនសមហេតុ ផលនោះ (វិធានការណ៍ ដែលគួរតែយកមកប្រើប្រាស់តែក្នុងករណី "លើកលែង") គ្រាន់តែផ្ដល់ទំងន់ដល់ការស្មានមើលថា បទចោទ គឺគ្រាន់ជាមធ្យោបាយក្នុងការបញ្ឈប់យុទ្ធនាការដែលកំពុងតែបន្ត របស់ពួកគេប៉ុណ្ណោះ។

ចាប់តាំងពីមាន ការចាប់ខ្លួនអ្នកស្រីអស់រយៈពេលជាងបីខែមក ហើយស្វាមីរបស់អ្នកស្រី យ៉ោម បុប្ផា បានព្យាយាម ផ្គត់ផ្គង់ជីវភាពក្នុងគ្រួសារ។ ក្នុងឋានៈជាអ្នកមើលថែរក្សាកូនប្រុស ហើយស្ថិតក្នុងស្ថានភាពសុខភាពខ្សោយផង លោកបានបង្ខំចិត្តឈប់ពីការងារ ហើយប្រើប្រាស់ប្រាក់សន្សំចុងក្រោយរបស់គ្រួសារ។ ជីវភាពគ្រួសារ គឺពឹងផ្អែកលើការជួលបន្ទប់នៅក្នុងផ្ទះរបស់លោកក្នុងតម្លៃ ៧០ ដុល្លារ ក្នុងមួយខែ។ អ្នកសហគមន៍តំបន់បឹងកក់ដទៃទៀត ក៏បានផ្ដល់ការគាំទ្រ និងជួយមើលថែកូនរបស់អ្នកស្រីនៅពេលដែលចាំបាច់ផងដែរ។ ម្ដាយរបស់អ្នកស្រី យ៉ោម បុប្ផា ក៏បានមកលេងពីខេត្តកំពង់ចាម នៅពេលណាដែលគាត់អាចមកបាន ទោះជាគាត់មានបញ្ហាសុខភាពផ្ទាល់ខ្លួនក៏ដោយ។

នៅមុនពេលឃុំខ្លួន អ្នកស្រី យ៉ោម បុប្ផា ចំណាយពេល ២ ម៉ោងជារៀងរាល់ល្ងាច ដើម្បីជួយបង្រៀនបន្ថែមកូន ដែលមានអាយុ ៨ ឆ្នាំ របស់អ្នកស្រី ឈ្មោះ លួស លីហួរ។ បច្ចុប្បន្ន លីហួរ បានប្រាប់ទៅម្ដាយរបស់ប្អូនថា ខ្លួនមានការលំបាកក្នុងការផ្ដោតលើការសិក្សានៅឯសាលារៀនណាស់ ហើយចំណាត់ថ្នាក់របស់ខ្លួនក៏បានធ្លាក់ចុះផងដែរ។ លីហួរអាចទៅសួរសុខទុក្ខម្ដាយរបស់ខ្លួននៅឯពន្ធនាគារម្ដង ឬ ពីរដងក្នុង មួយសប្ដាហ៍ ប៉ុន្តែគ្រួសារអ្នកស្រីនៅតែព្យាយាមទោះជាថ្លៃចំណាយខ្ពស់ក៏ដោយ (ជាទូទៅអ្នកទាំងនោះចំណាយប្រាក់ ១០.០០០ រៀល សម្រាប់ថ្លៃធ្វើដំណើរ ហើយ ២០.០០០ រៀល សម្រាប់ផ្ដល់ទៅឆ្មាំពន្ធនាគារ)។

អ្នកស្រី យ៉ោម បុប្ផា ត្រូវបានដាក់ក្នុងបន្ទប់ជាមួយស្ត្រីចំនួន ៦២ នាក់ផ្សេងទៀត រួមទាំងអ្នកស្រី ទឹម សាក់មុន្នី។ នៅ មណ្ឌលអប់រំកែប្រែទី២ ស្ត្រីត្រូវបានគេដាក់ឲ្យស្ថិតក្នុងស្ថានភាពភិតភ័យគ្មានអនាម័យ កកកុញ ហើយមិនមាន ឬមានការផ្ដល់សេវាពេទ្យតិចតួច។ អ្នកជាប់ពន្ធនាគារ ត្រូវតែបង់ថ្លៃទំនិញនានា ដូចជាទឹកស្អាតសម្រាប់បរិភោគ និងកន្លែងសម្រាប់ដេក។ បន្ទប់មានសភាពក្ដៅខ្លាំង ហើយមិនមានពន្លឺ ធម្មជាតិ និងខ្យល់ចូលបានគ្រប់គ្រាន់។ អ្នកដែលជាប់ឃុំបណ្ដោះអាសន្ន ត្រូវបានគេដាក់នៅក្នុងបន្ទាប់ជាមួយអ្នកដែលត្រូវបានផ្ដន្ទាទោសរួច ឬដាក់ពិរុទ្ធភាពរួច។

អ្នកស្រី យ៉ោម បុប្ផា នៅតែរក្សាភាពស្អាតស្អំ និងសង្ឃឹមថាយុត្តិធម៌នឹងត្រូវបានផ្ដល់មកអ្នកស្រី។ ប៉ុន្តែយុត្តិធម៌ អាចត្រូវ បានផ្ដល់ លុះត្រាតែអ្នកស្រីត្រូវបានទទួលការជំនុំជម្រះនៅមុខតុលាការដែលឯករាជ្យ និងអព្យាក្រឹត ហើយលុះត្រាតែអ្នកស្រីត្រូវបានទទួលការជំនុំជម្រះដោយយុត្តិធម៌ ដោយផ្អែកលើគោលការណ៍សន្មតជាមុនថាគ្មានទោស។ គួរឲ្យសោកស្ដាយយ៉ាងខ្លាំង ភាពទន់ខ្សោយនៃប្រព័ន្ធតុលាការនៅកម្ពុជា ទំនងជាមិនបានផ្ដល់ការការពារទាំងនេះដល់អ្នកស្រីនោទេ។



អ្នកស្រីបុប្ផា និយាយទៅកាន់អ្នកសារពត៌មានឆ្នាំ២០១២ បន្ទាប់ពីការតវ៉ា ដែលបានរៀបចំដោយប្រជាពលរដ្ឋបឹងកក់នៅរាជធានីភ្នំពេញ